# ឯកសារគោលជំហរ

## ឥទ្ធិពលនៃមុខងារដៃបឹងទន្លេសាប

**ខែកញ្ញា ឆ្នាំ ២០២២**

### សារតារ

ការសិក្សានេះមានគោលបំណងដើម្បីកំណត់រកនិងកត់ត្រាកត្តាសំខាន់ៗដែលរួមចំណែកឲ្យមានការប្រែប្រួលមុខងារដៃបឹងទន្លេសាប ជីវភាពប្រជាសហគមន៍និងជីវៈចម្រុះព្រមទាំងដើម្បីផ្តល់អនុសាសន៍ដល់ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីធ្វើឲ្យប្រាកដប្រជាពីនិរន្តរភាពជីវភាពនិងជីវៈចម្រុះនៅជុំវិញដៃបឹងទន្លេសាប ។ការសិក្សានេះបានត្រូវធ្វើឡើងនៅក្នុងខេត្តចំនួនប្រាំដែលមានដៃបឹងទន្លេសាប រួមមានស្ទឹងសែន ស្ទឹងស្រែង ស្ទឹងមោង (ដូនទ្រី) ស្ទឹងពោធិសាត់ និងស្ទឹងបរិបូរ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន បំពោះដៃដែលបាននាំទឹកចូលនិងចេញដោយផ្ទាល់ដល់បឹងទន្លេសាប ដោយប្រើប្រាស់ក្របខណ្ឌគោលគំនិតជីវភាពនិងជីវៈចម្រុះ ។

ការសិក្សានេះមានការចូលរួមពីបណ្តាមន្ទីរជំនាញជុំវិញខេត្តចំនួន ១៧ ស្រុកចំនួន ១០ ឃុំចំនួន ១៤ និងភូមិចំនួន ១៤ ក្នុងខេត្តចំនួន ៥ ដោយមានអ្នកចូលរួមឆ្លើយសំណួរសរុបទាំងអស់ចំនួន ៣៧៩ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៣៥ នាក់ ។ បែបបទវិធីសាស្ត្រមួយចំនួនត្រូវបានប្រើប្រាស់រួមមាន ការពិនិត្យទៅលើឯកសារដែលមានស្រាប់ ការធ្វើសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ការពិភាក្សាជាក្រុមតូចៗ ករណីសិក្សា និងការធ្វើសិក្ខាសាលាសុពលកម្មរបកគំហើញបឋម ។

បឹងទន្លេសាបនៅកម្ពុជា គឺជាបឹងទឹកសាបដ៏ធំជាងគេបង្អស់ក្នុងតំបន់អាស៊ីអគ្នេយ៍ ដែលទ្រទ្រង់ប្រជាពលរដ្ឋច្រើនជាងមួយលានអ្នក នឹងផ្តល់ជាប្រភពប្រូតេអ៊ីនដ៏ធំបំផុតសម្រាប់កំណើនពលរដ្ឋវ័យក្មេងរបស់កម្ពុជា ។ បច្ចុប្បន្ន បឹងទន្លេសាប គឺស្ថិតនៅក្រោមសម្ពាធដ៏ធ្ងន់ធ្ងរ ។ មានការគម្រាមកំហែងជាច្រើនដល់ប្រព័ន្ធជីវៈចម្រុះបឹងទន្លេសាប ដោយរាប់បញ្ចូល ការទាញយកផលនេសាទនិងធនធានសត្វព្រៃហួសកម្រិត ការទន្ទ្រានឆៅរដូវប្រាំង និងការកាប់ព្រៃលេចទឹកយកដី ។

សម្ពាធសីតុណ្ហភាពនៅក្នុងតំបន់អាស៊ីអគ្នេយ៍បានកើនឡើងនៅចន្លោះពី ០.១ និង ០.៣ អង្សាសែលសីសក្នុងទសវត្សនីមួយៗរវាងឆ្នាំ១៩៥១និងឆ្នាំ ២០០០ (ADB 2009) ។ កម្រិតកំពស់ទឹកសមុទ្របានកើនឡើងនូវអាត្រាពី

១ ទៅ ៣ មីលីម៉ែត្រក្នុងមួយឆ្នាំ ចាប់តាំងតែពី ៤០ ឆ្នាំកន្លងទៅ ។ ព្រឹត្តិការណ៍ភ្លៀងធ្លាក់ធ្ងន់ធ្ងរបានកើនឡើងជាសំខាន់នៅចន្លោះឆ្នាំ ១៩០០ និង ២០០៤ ដែលមានព្យុះស៊ីក្លូនបានកើតឡើងជាញឹកញាប់នៅចន្លោះឆ្នាំ ១៩៩០ និង ឆ្នាំ ២០០៣ (ADB 2009) ។ ប្រទេសកម្ពុជា ត្រូវបានគេព្យាករណ៍ថានឹងទទួលរងសម្ពាធកំដៅ ៣.១ អង្សាសេលសីស នៅទសវត្ស ២០៩០ ដោយធៀបនិងលក្ខខណ្ឌដើមគ្រានៅឆ្នាំ ១៩៨៦ ដល់ ឆ្នាំ ២០០៤ ដែលស្ថិតក្រោមបរន្តបញ្ចូនយ៉ាងខ្ពស់ ។ ការប្រែប្រួលរបត់ទឹកភ្លៀងចាប់តាំងពីទសវត្ស ១៩២០ កើនឡើងមិនទៀងទាត់ មិនអាចព្យាករណ៍បាន និងមានភ្លៀងធ្លាក់ធ្ងន់ធ្ងរ ដែលញាំងជីវភាពកសិករទាំងឡាយទទួលរងឥទ្ធិពលយ៉ាងអាក្រក់ ។

ការប្រែប្រួលអាកាសធាតុ គឺកំពុងគម្រាមគំហែងដល់របត់ទឹកហូរជាលក្ខណៈធម្មជាតិរបស់ដៃបឹងទន្លេសាបទាំង ១១ ដែលចូលរួមនាំទឹកបាក់បំពេញបឹងទន្លេសាប ។ ដៃបឹងទន្លេសាបក្នុងខេត្តកំពុងធំ សៀមរាប បាត់ដំបង ពោធិសាត់ និងកំពុងឆ្នាំងបានកំពុងទទួលរងបំរែបំរួលនេះហើយ ដែលបណ្តាលមកពីភ្លៀងធ្លាក់មិនគ្រប់គ្រាន់ និងមិនទៀងទាត់ ព្រមទាំងមានទឹកជំនន់មិនទៀងទាត់និងមានភាពអសកម្មបំពោះការការហូរទឹកបាក់ត្រឡប់ពីបឹងទន្លេសាបមកវិញអំឡុងរដូវប្រាំង ។ កំណើនប្រជាពលរដ្ឋបានចូលរួមចំណែកយ៉ាងធំដល់និរន្តរភាពប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះនៅតាមមូលដ្ឋាន ល្គឹកដែលការអនុវត្តច្បាប់នៅមានភាពធូររលុង កង្វះការខិតខំចូលរួមចំណែកនិងការសម្របសម្រួលនៃរាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រាលសម្ពាធពីការទាញយកធនធានធម្មជាតិហួសកម្រិត ។ សកម្មភាពនេសាទនិងបរបាញ់ខុសច្បាប់ ការកាប់ឆ្ការនិងដុតព្រៃលេចទឹក ការបោះបោលកាកសំណល់ពុល ការបាក់ដី និងការចាក់ដីបំពេញ គឺកើតមានឡើងជាប្រចាំដោយគ្មានការត្រួតពិនិត្យនៅក្នុងបឹងទន្លេសាបនិងតាមដៃបឹងទន្លេសាបទាំងប្រាំ ។

ការបាត់បង់ជាសំខាន់បានកើនឡើងទៅលើរុក្ខជាតិ សត្វក្នុងទឹកនិងលើគោក នៅតាមដៃបឹងទន្លេសាប ។ ដូចគ្នាដែរ ជីវភាពពឹងអាស្រ័យលើផលផល គឺមានការចុះថយជាយថាហេតុ ដោយសារផលនេសាទមានការធ្លាក់ចុះជាបន្តបន្ទាប់ ។ គ្រួសារដែលពឹងអាស្រ័យជីវភាពលើធនធានផលផល គឺកំពុងរងផលប៉ះពាល់យ៉ាងខ្លាំង។ ទឹកជំនន់និងការអូសបន្លាយរដូវប្រាំងបានបន្តបន្ថយកម្រិតប្រាក់ចំណូលនិងស្បៀងអាហាររបស់គ្រួសារជាច្រើន ដែលពឹងអាស្រ័យលើរបបទឹកភ្លៀងនិងទឹកស្ទឹងសម្រាប់ផលិតកម្មកសិកម្ម ។ទន្ទឹមគ្នាដែរ តម្លៃធាតុចូលកសិកម្មកើនឡើង ក៏ប៉ុន្តែតម្លៃផលិតផលកសិកម្មធ្លាក់ចុះយ៉ាងគំហុក ។ ការណ៍ទាំងនេះ បានបង្ខំឲ្យគ្រួសារមូលដ្ឋានជាច្រើនស្វះស្វែងរកមុខរបរជាជម្រើសផ្សេងៗដើម្បីទ្រទ្រង់តម្រូវការស្បៀងអាហារនិងប្រាក់ចំណូលរបស់ផងគេ ។ គ្រួសារមួយចំនួនបានបញ្ជូនសមាជិកគ្រួសាររបស់គេទៅធ្វើការនៅតាមរោងចក្រកាត់ដេរ ការដ្ឋានសំណង់ និងការងារផ្សេងៗទៀតនៅក្រៅសហគមន៍ដែលបានទទួលប្រាក់កម្រៃ ។ គ្រួសារភាគខ្លះបានចាកចេញទៅខេត្តផ្សេងៗ ឬទីក្រុងផ្សេងៗនៃកម្ពុជា ឬប្រទេសថៃដើម្បីស្វះស្វែងរកការងារធ្វើ ។

កំណើនស្ត្រីជនបទក្នុងសកម្មភាពសេដ្ឋកិច្ច គឺមានទំនាក់ទំនងយ៉ាងជាក់ច្បាស់ជាមួយការផ្លាស់ប្តូរមុខរបរ និងតម្រូវការឱកាសការងារក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធនៅមូលដ្ឋាននិងខាងក្រៅ ។ ទាំងបុរសនិងស្ត្រីធ្វើការប្រឹងប្រែងជាងមុនទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ននេះ ដើម្បីជួយសម្រាលតម្រូវការនិងបន្ទុកបំណុលគ្រឹះស្ថានធនាគារឬមីក្រូហិរញ្ញវត្ថុទាំងឡាយ ។ ការផ្លាស់ប្តូរតួនាទីរបស់បុរសគឺស្តែងឡើងក្នុងការគាំទ្រដៃគូរបស់គេ ក្នុងខណៈដែលស្ត្រីមានការប៉ុនប៉ងមាំមួនជាងមុនដើម្បីចូលប្រឡូកក្នុងការងារដែលបានទទួលប្រាក់កម្រៃ ។ មនុស្សវ័យចំណាស់គឺត្រូវទទួលបន្ទុកមើលថែចៅៗ នៅពេលដែលឪពុកម្តាយរបស់គេបានធ្វើចំណាកស្រុកដើម្បីធ្វើការនៅឆ្ងាយពីលំនៅដ្ឋាន ។ គ្រួសារបំណាកស្រុកជាញឹកញយមិនអាចរក្សាឲ្យកូនៗរបស់ផងគេបន្តសិក្សានៅឯសាលារៀនបានឡើយ ។ មានកុមារជាច្រើនបានឈប់ពីសាលានៅកម្រិតការអប់រំបឋមរបស់គេ ។ កុមារៗទាំងនោះទំនងជាបានចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលដើម្បីរួមចំណែកទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ ។

រាជរដ្ឋាភិបាលមូលដ្ឋាន កំពុងពុះពារដើម្បីអនុវត្តច្បាប់ជាធរមាន ការបែករំលែកគម្រូអនុវត្តល្អៗ ស្របទៅតាមគោលនយោបាយជាតិនានាសម្រាប់បុព្វហេតុនៃនិរន្តរភាពធនធានធម្មជាតិ ដោយមានការណែនាំយ៉ាងត្រឹមត្រូវពីរាជរដ្ឋាភិបាលថ្នាក់ជាតិ។ មានគំនិតផ្តួចផ្តើមមួយចំនួនកំពុងមានប្រសិទ្ធភាពរួមមាន ការលើកកម្ពស់ការយល់ដឹងប្រជាសហគមន៍អំពីការបំពុលទឹក ការគ្រប់គ្រងកាកសំណល់ ការការពារបរិស្ថាន ការការពារសកម្មភាពនេសាទនិងការកាប់ព្រៃខុសច្បាប់ ។ ការសម្របសម្រួលឲ្យមានការតាំងទីលំនៅឡើងវិញនៅលើគោគរបស់គ្រួសាររស់នៅលើទឹក និងការផ្តល់កម្មសិទ្ធដីធ្លីដល់ពួកគេ គឺជាជំហានដ៏ល្អមួយដើម្បីកាត់បន្ថយសម្ពាធលើធនធានធម្មជាតិ ។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការយល់ដឹងដូចខាងលើរបស់គ្រួសារមូលដ្ឋាននិងផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្ម សមត្ថភាពស្ថាប័នដល់អង្គការសហគមន៍ ការផ្តល់ធាតុចូលកសិកម្ម និងការគាំទ្រការសម្របសម្រួលទីផ្សារសម្រាប់ផលិតផលកសិកម្មរបស់ពួកគេ ។

## សារជាគន្លឹះ

1. ការអនុវត្តច្បាប់គឺសំខាន់ដើម្បីជួយដល់និរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិ ។ រាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិមានការប៉ុនប៉ងយ៉ាងមាំមួនដើម្បីអនុវត្តច្បាប់នានាជាធរមានពាក់ព័ន្ធនិងនិរន្តរភាពធនធានធម្មជាតិ ។ ក៏ប៉ុន្តែការអនុវត្តច្បាប់នេះមានលក្ខណៈមិនជាប់លាប់ ដោយសារការបាត់រំលែកថវិកាមិនបានគ្រប់គ្រាន់ដើម្បីអាចទប់ទល់នឹងបញ្ហានានាដែលកំពុងរីករាលដាលក្នុងខេត្តនីមួយៗ កង្វះជំនាញក្នុងចំណោមមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ កង្វះការសម្របសម្រួលដោយហ្មត់ចត់និងកិច្ចសហប្រតិបត្តិការក្នុងចំណោមមន្ទីរជំនាញ

ជុំវិញខេត្ត អាជ្ញាធរ ដែនដី និងអង្គការសង្គមស៊ីវិលទាំងឡាយ ។ ការគាំទ្រពីសំណាក់ក្រសួងជំនាញនៅកម្រិតជាតិស្តីពីការ អភិវឌ្ឍវារីវប្បកម្មប្រើនស្ថិតនៅលើមូលដ្ឋានអាណត្តិគម្រោង និងកង្វះភាពស៊ីសង្វាក់គ្នាដើម្បីអាចពង្រីកកិច្ចអន្តរាគមន៍ណាមួយ ។

## ***ការសង្កេតទី ១***

នៅក្នុងទិដ្ឋភាពនេះ ការបាត់រំលែកថវិកាឲ្យបានគ្រប់គ្រាន់និងការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធនានាក្នុងការអនុវត្តច្បាប់ គួរតប្បីជាអាទិភាពចម្បងដើម្បីជួយឲ្យមាននិរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិ៕

2. គ្រួសារមូលដ្ឋានមានការយល់ដឹងភាគខ្លះអំពីច្បាប់នានាជាធរមាន ក្របខណ្ឌគតិយុត្ត និងគម្រូអនុវត្តល្អៗទាក់ទងនិងការការពារបរិស្ថាន ការអភិរក្សនិងការការពារមច្ឆជាតិជាដើម ។ រាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលទាំងឡាយមានគោលបំណងរួមគ្នាដើម្បីញ៉ាំងការចូលរួមរបស់គ្រួសារមូលដ្ឋាននានាក្នុងការការពារ និងអភិរក្សបរិស្ថានព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិ ។ គំរូអនុវត្តជាយុទ្ធសាស្ត្រនានានឹងជួយឲ្យការយល់ដឹងក្នុងបំណោមគ្រួសារមូលដ្ឋានទាំងនោះកាន់តែផុសផុលឡើង និងតាមដានការផ្លាស់ប្តូរឥរិយាបថនានានៅកម្រិតបុគ្គលគ្រួសារ ប្រសិនបើមានគំរូអនុវត្តជាយុទ្ធសាស្ត្រទាំងនោះ ។ វាទាមទារឲ្យមានការខិតខំរយៈពេលវែង ដោយមានបែបបទជាប្រព័ន្ធដើម្បីញ៉ាំងផ្នត់គំនិតរបស់ពួកគេឲ្យស្រឡាញ់ធម្មជាតិ ខណៈដែលពួកគេពឹងអាស្រ័យជីវភាពនៅលើធនធានទាំងនោះ ។

## ***ការសង្កេតទី ១***

ការពិចារណាគួរតប្បីធ្វើទៅលើការដាក់ឲ្យមានបែបបទជាប្រព័ន្ធ (មិនមែនតាមអាណត្តិ គម្រោង) ដើម្បីបង្កើនការយល់ដឹងដល់ប្រជាសហគមន៍អំពីច្បាប់ដែលពាក់ព័ន្ធ ក្របខណ្ឌគតិយុត្តិនិងគម្រូវអនុវត្តល្អៗទាក់ទងនិងការការពារនិងការអភិរក្សធនធានធម្មជាតិ រាប់បញ្ចូល ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីដែលមានក្នុងមូលដ្ឋាន ។

3. គម្របព្រៃលិចទឹកទាំងឡាយកំពុងតែបាត់បង់បន្តិចម្តងៗ ដោយមានកម្រិតវិនាសកម្មខុសៗគ្នាក្នុងខេត្តដែលបានសិក្សានីមួយៗ ។ ការណ៍នេះបណ្តាលមកពីការកាប់ព្រៃនិងការទន្ទ្រានយកដីដោយគ្មានការគ្រប់គ្រងសម្រាប់ពង្រីកផលិតកម្មកសិកម្ម គោលបំណងអាជីវកម្ម និងឯកជនូបនីយកម្មទៅលើដីរបស់រដ្ឋ ។ ជាឧទាហរណ៍ គម្របព្រៃលិចទឹកនៅក្នុងឃុំទាំង ១១ ក្នុងស្រុកបរិបូរ និងព្រៃលិចទឹកនានាក្នុងតំបន់បឹងទន្លេសាបត្រូវបានកាប់ឆ្ការនិងដុតបំផ្លាញដោយគ្រួសារមូលដ្ឋានស្ទើរតែរៀងរាល់ឆ្នាំ ។ ការបាត់បង់ធ្ងន់ធ្ងរនេះស្តែងចេញជាងគេនៅក្នុងស្រុកមោងឫស្សី ស្រុករុក្ខគីរី និងតាមបណ្តោយស្ទឹងស្រែងដែលមានចំនួន ១០៧៩ ហិកតាក្នុងឆ្នាំ ២០១២ និងចំនួន ៤០ ហិកតាទៀតក្នុងចំណោម ៣១០០ ហិកតាជាសរុបដែលនៅសេសសល់នាពេលបច្ចុប្បន្ន ។ មានការបាត់បង់យ៉ាងធំណាំទៅលើរុក្ខជាតិ មច្ឆជាតិ និងសត្វទាំងឡាយ ។

## ***ការសង្កេតទី ៣***

នៅទីណាដែលអាចធ្វើទៅបាន និងដោយផ្តល់អាទិភាពនូវវិត្តមានជាចាំបាច់នៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីការស្តារនិតិសម្បទាចំពោះគម្របព្រៃលិចទឹក គឺជាការយកចិត្តទុកដាក់ជាសំខាន់របស់ស្ថាប័នពាក់ព័ន្ធនានាសម្រាប់ការលើកគម្រោងអន្តរាគមន៍ទាំងឡាយនៅពេលបច្ចុប្បន្ននិងអនាគត ។

4. មន្ទីរធនធានទឹកនិងឧតុនិយម គឺជាស្ថាប័នដឹកនាំក្នុងការសាងសង់ទំនប់នានាឆ្លងកាត់ដៃបឹងទន្លេសាបទាំងឡាយ ។ សហគមន៍កសិករអ្នកប្រើប្រាស់ទឹក គឺត្រូវបានបង្កើតឡើងដើម្បីរក្សានិរន្តរភាពគម្រោងធារាសាស្ត្រ ក្រោយត្រូវបានសាងសង់បញ្ចប់ ។ ទំនប់ទាំងឡាយនោះបានកំពុងបង្កើតបរន្តទឹកហូរចូលនិងចេញមិនប្រក្រតី ហើយទំនងជាកត្តាកំណត់កម្រិតទឹកនៅខាងក្រោមខ្សែទឹកអំឡុងរដូវប្រាំងផងដែរ ។ ជាវិជ្ជមាន គម្រោងធារាសាស្ត្រទាំងឡាយអាចរក្សាកម្រិតទឹកនៅអំឡុងរដូវប្រាំងបាន ដើម្បីបង្កលក្ខណៈឲ្យរស់រានឡើងវិញនូវជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីតាមមូលដ្ឋាន ជាឧទាហរណ៍ នៅខ្សែទឹកខាងលើ នៃស្ទឹងមោង បាននាំបណ្តាលឲ្យមានផលនេសាទត្រីកើនឡើងបន្តិចបន្តួចដែរនៅអំឡុងពេលរដូវវស្សា ។ បំណែកគម្រោងធារាសាស្ត្របំនួនបួនទៀតដែលកំពុងស្ថិតក្រោមការសាងសង់ក្នុងឃុំ តាអាន ខេត្តឧត្តរមានជ័យ និងក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ អាចរក្សា បរិមាណទឹកបានពេញមួយឆ្នាំ ។ ជាអវិជ្ជមានវិញ គ្រួសារមូលដ្ឋានទាំងឡាយដែលរស់នៅតាមខ្សែទឹកកណ្តាល និងក្រោម មានការខ្វះខាតទឹកសម្រាប់ស្រោចស្រពដំណាំនៅអំឡុងរដូវប្រាំង ឧទាហរណ៍ កម្រិតទឹកក្នុងបឹងទន្លេសាបមានសភាពរាក់ ដែលមិនអាចហូរត្រឡប់ទៅស្ទឹងបរិបូរវិញបាន ។ ចាប់តាំងពីពីរបីឆ្នាំកន្លងទៅ គ្រួសារមូលដ្ឋានទាំងឡាយដែលរស់នៅតាមបណ្តោយស្ទឹងបរិបូរ ក្នុងស្រុកបរិបូរ តែងតែប្រឈមនិងកង្វះ

ខាតទឹកនៅអំឡុងរដូវប្រាំង ដើម្បីស្រោចស្រពដំណាំនិងបម្រើការប្រើប្រាស់សម្រាប់គ្រួសារ ។ កម្រិតទឹកនៅអំឡុងរដូវប្រាំងមិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ដល់សកម្មភាពកសិកម្មនិងការចិញ្ចឹមសត្វ ហើយរដូវប្រាំងមានរយៈពេលវែង ។ ស្ទឹងផ្នែកខ្លះមានការរីងស្ងួតនៅអំឡុងរដូវប្រាំងក្នុងស្រុកក្រវ៉ាញ ។

## ការសង្កេតទី ៤

តាមដែលអាចធ្វើទៅបាន ការពិចារណាដើម្បីឲ្យជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីមាននិរន្តរភាព គួរគប្បីពិនិត្យជាសំខាន់ទៅលើការវិភាគតម្លៃសេដ្ឋកិច្ចនិងសង្គមដើម្បីកំណត់លទ្ធភាពសម្រាប់ការកសាងទំនប់វារីអគ្គីសនី ។ ដូច្នេះ ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធនានាគួរបើកទូលាយ ដោយរាប់បញ្ចូល អង្គការសង្គមស៊ីវិល សហគមន៍ វិស័យឯកជន ។ល។ ក្នុងដំណើរការវាយតម្លៃមុនពេលការសាងសង់ ដែលជាចំណុចចាប់ផ្តើមដើម្បីធានាការបែងចែកផលប្រយោជន៍ឲ្យមានភាពសមរម្យ ។

5. ការធ្លាក់ចុះផលនេសាទ គឺមានផលប៉ះពាល់យ៉ាងជាក់ស្តែងដល់លទ្ធភាពនៃការរស់រានរបស់គ្រួសារជាច្រើនដែលពឹងអាស្រ័យជាខ្លាំងលើធនធានជលផល ។ សម្រាប់គ្រួសារដែលរស់នៅក្នុងតំបន់ ៣ នៃតំបន់វាលទំនាប (ឱទារហាណ៍ ឃុំផាត់សណ្តាយ) មានចំនួនច្រើនជាង ៩០ ភាគរយដែលធ្វើការរស់នៅលើធនធានជលផល ហើយមានចំនួនគ្រួសារតិចតួចប៉ុណ្ណោះបានចូលរួមសកម្មភាពកសិកម្ម (ការដាំដុះនិងការចិញ្ចឹមសត្វ) និងអាជីវកម្មខ្នាតតូច ។ មានគ្រួសារភាគតិចដែលរស់នៅតាមខ្សែទឹកខាងលើបានទទួលរងផលប៉ះពាល់ពីការធ្លាក់ចុះនៃផលនេសាទ ពីព្រោះថាពួកគេភាគច្រើនមិនពាក់ព័ន្ធនិងធនធានជលផលជាជីវភាពចម្បងរបស់ពួកគេឡើយ ។ ប្រាក់ចំណូលរបស់ប្រជាសហគមន៍ដែលរស់នៅខ្សែទឹកកណ្តាលនិងក្រោមបានទទួលរងផលប៉ះពាល់កម្រិតធ្ងន់ធ្ងរដោយការធ្លាក់ចុះផលនេសាទ (ក្នុងខេត្តសៀមរាប បាត់ដំបង និងពោធិសាត់) ។

កង្វះខាតទឹកស្ទឹង គឺជាបញ្ហាអាយុជីវិតដល់និរន្តរភាពជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងផលិតកម្មកសិកម្ម ។ ជីវភាពដែលពឹងអាស្រ័យលើការងារកសិកម្មរបស់ពួកគេ គឺជាប្រភពចម្បងសម្រាប់ស្បៀងអាហារនិងប្រាក់ចំណូល គឺកំពុងទទួលរងការគម្រាមគំហែងពីទឹកជំនន់ និងគ្រោះរាំងស្ងួតអូសបន្លាយ ។ នៅក្នុងពេលដដែលនេះ តម្លៃផលិតកម្មកសិកម្មកើនឡើង ហើយថ្លៃលក់ផលិតផលកសិកម្មវិញ មានការធ្លាក់ចុះ ដែលញាំងគ្រួសារមូលដ្ឋានជាច្រើនមានសង្ឃឹមតិចតួចសម្រាប់ការស្តារជីវភាពរបស់ពួកគេ ។

ការណ៍ទាំងនេះបានរុញច្រានឱ្យមានពិពិធកម្មប្រាក់ចំណូល ដែលមានគ្រួសារជាច្រើនបានចូលរួមជាស្រេប ហើយក្នុងការងារសំណង់ ការងារតាមរោងចក្រកាត់ដេរ ការបើកអាជីវកម្មខ្នាតតូច និងការងារក្រៅកសិដ្ឋានផ្សេងៗទៀត ។ មានគ្រួសារមួយចំនួនបានធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីស្វះស្វែងរកការងារ ដែលជាមធ្យោបាយរក្សាលំនឹងជីវភាពនិងការរស់នៅជាមួយនិងបំណុលរបស់គ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុទាំងឡាយ ។ យុវជន ជាពិសេសស្ត្រី មានការកើនឡើងក្នុងការងាររោងចក្រ ដែលមានទីតាំងអាជីវកម្មក្នុងខេត្តពោធិសាត់និងខេត្តកំពុងឆ្នាំង ។

## *ការសង្កេតទី ៤*

អន្តរាគមន៍លើការអភិវឌ្ឍន៍ជីវភាពសម្រាប់គ្រួសារដែលទទួលរងផលប៉ះពាល់នៅតាមដៃបឹងទន្លេសាបគួរគប្បីមានលក្ខណៈជាយុទ្ធសាស្ត្រ មានលទ្ធភាពខាងសេដ្ឋកិច្ចសង្គម និងអាចពង្រីកបាន ដើម្បីជួយឱ្យប្រជាសហគមន៍ទាំងនោះអាចធ្វើការនិងរស់ដោយសមរម្យនៅលើដីរបស់គេបាន ។